01032283

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**លេខ/N°: A117/2/2**

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងលេខ: ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ១២)

ចំពោះមុខ: **ចៅក្រម ប្រាក់ គីមសាន ប្រធាន**
**ចៅក្រម Rowan DOWNING**
**ចៅក្រម ន័យ ថុល**
**ចៅក្រម Chang-Ho CHUNG**
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៤

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 04/11/2014
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

---

**សាធារណៈ: (សំណៅកោសលុប)**

**សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មត លើសំណើលើកទីបួនរបស់ [redacted] សុំបំពេញកិច្ចស៊ើបសួរ**

---

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍**

មុំ លុជ
Richard ROGERS
Göran SLUITER

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ÷**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉េន ពៅ
Annie DELAHAIE
Laure DESFORGES
Emmanuel JACOMY
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មតលើសំណើលើកទីបួនរបស់ [redacted] សុំបំពេញកិច្ចស៊ើបសួរ" ដែលបានដាក់កាលពីថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤ ("បណ្តឹងឧទ្ធរណ៍")[1]។

## I. សេចក្តីផ្តើម

1. បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងសំណើសុំបំពេញកិច្ចស៊ើបសួរដែល [redacted] ("ម្ចាស់បណ្តឹងឧទ្ធរណ៍") បានដាក់កាលពីថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ លើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") បានណែនាំក្រឡាបញ្ជី មិនឱ្យដាក់ទៅក្នុងផ្នែកអង្គសេចក្តីនៃសំណុំរឿងសម្រាប់ឱ្យសហចៅក្រមស៊ើបអង្កេតពិចារណាទេ ដោយយោងទៅលើការយល់ឃើញមុនៗរបស់គាត់ថា ម្ចាស់បណ្តឹងឧទ្ធរណ៍ពុំមានសិទ្ធិដាក់សំណើសុំបំពេញកិច្ចស៊ើបសួរទេ។

## ក. ប្រវត្តិនីតិវិធី

2. កាលពីថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ស.ច.ស.អ បានបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី ដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់ ដោយផ្អែកលើមូលដ្ឋានថា ក្នុងនាមជា ("ជនសង្ស័យ") គាត់ពុំមានសិទ្ធិដាក់សំណើសុំបំពេញកិច្ចស៊ើបសួរនៅក្នុងដំណាក់កាលនេះឡើយ ("សេចក្តីសម្រេចលើសំណើសុំចំនួនបី")[2]។ ស.ច.ស.អ បានលើកឡើងថា "ប្រសិនបើគ្មានការប្រែប្រួលឋានៈរបស់ជនសង្ស័យទេ គាត់នឹងមិនទទួលយក ហើយក៏មិនដាក់ចូលក្នុងសំណុំរឿងនូវសំណើបន្ថែមទៀតដែលដាក់ក្នុងនាមជនសង្ស័យ ដើម្បីស្នើឱ្យអនុត្តសិទ្ធិដែលវិធានផ្ទៃក្នុងរក្សាទុកឱ្យជនត្រូវចោទ"[3]។ សេចក្តីសម្រេចនេះ ត្រូវបានចេញបន្ទាប់ពីសេចក្តីសម្រេចមុនៗចំនួនពីរដែល ស.ច.ស.អ បានសម្រេចថា ម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលមិនមែនជា "ជនត្រូវចោទ" មិនមានសិទ្ធិចូលរួមនៅក្នុងកិច្ចស៊ើបសួរនាដំណាក់កាលនេះបានទេ[4] ក៏ដូចជាបណ្តឹងឧទ្ធណ៍ដែលមិនទទួលបានជោគជ័យមួយដែល

---

[1] ឯកសារ A117/2/1។

[2] សេចក្តីសម្រេចរងការជំទាស់ កថាខណ្ឌ ៥។

[3] *ដូចខាងលើ* កថាខណ្ឌ ៦។

[4] សេចក្តីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តី [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងការស៊ើបអង្កេត ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ D121/4។ ដីកាសម្រេចលើសំណើសុំឱ្យពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់ ស.ច.ស.អ លើសំណើសុំរបស់ក្រុមមេធាវីការពារក្តី [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងការស៊ើបអង្កេត ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D121/4/6។

ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់បញ្ហានេះនៅចំពោះមុខអង្គបុរេជំនុំជម្រះដែរ[5]។ កាលពីថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៤ ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំចំនួនបី ទៅអង្គបុរេជំនុំជម្រះ (“បណ្តឹងឧទ្ធរណ៍លើសំណើសុំចំនួនបី”)[6]។

[redacted] នៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់សំណើលើកទីបួនសុំបំពេញកិច្ចស៊ើបសួរ (“សំណើលើកទីបួន”)[7] ដោយស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត “[redacted]

4. នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ក្រឡាបញ្ជីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ថា ស.ច.ស.អ បានណែនាំគាត់ “មិនឱ្យដាក់សំណើទីបួនទៅក្នុងផ្នែកអង្គសេចក្តីនៃសំណុំរឿង ០០៤ នាពេលនេះទេ (“សេចក្តីជូនដំណឹង”)[9]។ សេចក្តីជូនដំណឹងនេះរម្លឹកឡើងវិញអំពីការលើកឡើងរបស់ ស.ច.ស.អ នៅក្នុងដីកាសម្រេចរបស់គាត់លើសំណើសុំចំនួនបី និងការកត់សម្គាល់ថា ឋានៈរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍មិនមានការប្រែប្រួលឡើយ[10]។ សេចក្តីជូនដំណឹងនេះបានបញ្ជាក់បន្ថែមទៀតថា អនុលោមតាមវិធាន ៧៧(១១) នៃវិធានផ្ទៃក្នុង បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំចំនួនបី ដែលកំពុងតែរង់ចាំការសម្រេចសេចក្តីនោះ មិនមានអានុភាពព្យួរការអនុវត្តដីកាសម្រេចនេះបានឡើយ[11]។ សំណើទីបួនត្រូវបានដាក់បញ្ចូលទៅក្នុងផ្នែករដ្ឋបាលនៃសំណុំរឿង ០០៤ ដោយក្រឡាបញ្ជីរបស់ការិយាល័យសហចៅក្រម

---

[5] ការពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធសំណើសុំពិនិត្យសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេត ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D121/4/1/4។

[6] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើនានារបស់ [redacted] សុំបំពេញកិច្ចស៊ើបសួរ ដែលបានដាក់ជាភាសាអង់គ្លេសកាលពីថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៤ និងជាភាសាខ្មែរ កាលពីថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D190/1/1។

[7] សំណើសុំបំពេញកិច្ចស៊ើបសួរលើកទីបួន ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ A117/1។

[8] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧។

[9] អនុស្សរណៈពីការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្ញើជូនសហមេធាវីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលមានកម្មវត្ថុ “សេចក្តីជូនដំណឹងស្តីពីសំណើទីបួនរបស់ [redacted] សុំបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៤ ប៉ុន្តែ អនុស្សរណៈនេះត្រូវបានដាក់ និងជូនដំណឹងនៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ A117។

[10] សេចក្តីជូនដំណឹង កថាខណ្ឌ ២-៣។

[11] សេចក្តីជូនដំណឹង កថាខណ្ឌ ៣។

01032286



ស៊ើបអង្កេត ជាឧបសម្ព័ន្ធមួយភ្ជាប់ទៅនឹងសេចក្តីជូនដំណឹងនេះ។ ការធ្វើបែបនេះ គឺស្ថិតក្នុងទម្រង់អនុវត្តនាពេលថ្មីៗរបស់ ស.ច.ស.អ ក្នុងការដាក់ "សំណើសុំទាំងអស់របស់ជនសង្ស័យ" ទៅក្នុងផ្នែករដ្ឋបាលនៃសំណុំរឿង "ដើម្បីរក្សាទុកជាកំណត់ហេតុប៉ុណ្ណោះ ប្រសិនបើជនសង្ស័យណាម្នាក់ត្រូវបានសម្រេចថា មានសិទ្ធិក្នុងករណីជាក់លាក់ ឬប្រសិនបើឋានៈរបស់គាត់ជាជនសង្ស័យបានផ្លាស់ប្តូរនៅដំណាក់កាលក្រោយមកទៀត"[12]។

## ខ. បណ្តឹងឧទ្ធរណ៍

5. ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់បណ្តឹងឧទ្ធរណ៍ នៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤ ដោយជំទាស់តវ៉ាថា ការដាក់សំណើលើកទីបួនទៅក្នុងផ្នែករដ្ឋបាលនៃសំណុំរឿង និងការមិនបានសម្រេចលើសំណើនេះអស់រយៈពេលបីខែមកហើយនោះ ស.ច.ស.អ បានបដិសេធបណ្តឹងឧទ្ធរណ៍នេះ "តាមការសន្មត"[13]។ ម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបានដោយអនុលោមតាមវិធាន ៧៣(ក) និងវិធាន ៧៤(៣)(ខ) ដែលបានបកស្រាយដោយយោងទៅលើវិធាន ២១ នៃវិធានផ្ទៃក្នុង ដោយសារបណ្តឹងឧទ្ធរណ៍នេះ ពាក់ព័ន្ធនឹងការបដិសេធតាមការសន្មតចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរ[14]។ ម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងបន្ថែមទៀតថា បណ្តឹងឧទ្ធរណ៍នេះក៏អាចទទួលយកបានដោយអនុលោមតាមវិធាន ២១ តែមួយដែរ ដោយហេតុថា បណ្តឹងឧទ្ធរណ៍ "ពាក់ព័ន្ធនឹងសមភាព និងភាពយុត្តិធម៌នៃការស៊ើបអង្កេត ព្រមទាំងសិទ្ធិរបស់ [ម្ចាស់បណ្តឹងឧទ្ធរណ៍] ក្នុងការទទួលបានការការពារខ្លួនប្រកបដោយប្រសិទ្ធភាព និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័ស"[15]។ ចំពោះអង្គសេចក្តីវិញ ម្ចាស់បណ្តឹងឧទ្ធរណ៍អះអាងថា ស.ច.ស.អ មានកំហុស "ក្នុងការអនុវត្តតាមគោលនយោបាយទូទៅ" ដោយមិនពិចារណាលើសំណើសុំបំពេញកិច្ចស៊ើបសួរនោះទេ[16] និងការដាក់បញ្ចូលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីបួន ទៅក្នុងផ្នែករដ្ឋ

---

12 ដីកាសម្រេចលើសំណើរបស់ [ជនសង្ស័យ] ទៅសហចៅក្រមស៊ើបអង្កេត សុំបង្គាប់ទៅក្រឡាបញ្ជីរបស់ ក.ស.ច.ស ឱ្យបញ្ចូលនូវការដាក់ឯកសារនានារបស់មេធាវីការពារក្តីទៅក្នុងសំណុំរឿងភ្លាម ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ D202/2។ *សូមមើល ផងដែរ* សំណុំរឿង ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើសំណើរបស់ [ជនសង្ស័យ] សុំឱ្យដាក់សំណើសុំការពិចារណាទាំងអស់ទៅក្នុងសំណុំរឿង ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D108/1។

13 បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២, ១៧-១៩។

14 បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៧-១៩។

15 បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២០។

16 បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២១-២៥។

បាលនៃសំណុំរឿងដោយមិនត្រឹមត្រូវ ដោយមិនដាក់បញ្ចូលទៅក្នុងផ្នែកអង្គសេចក្តីនោះ[17]។ ម្ចាស់បណ្តឹងឧទ្ធរណ៍ក៏បានយោងទៅទស្សីករណ៍នានា នៅក្នុងបណ្តឹងឧទ្ធរណ៍លើសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបីរបស់គាត់ ដែលបានដាក់ជូនអង្គបុរេជំនុំជម្រះដែរ[18]។

6. សហព្រះរាជអាជ្ញា ឬមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនបានដាក់ចម្លើយតបនៅក្នុងរង្វង់ពេលវេលា ដែលច្បាប់បានកំណត់នោះទេ។

### ខ. ការវិវត្តបន្ថែមទៀត

7. នៅថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤ អង្គបុរេជំនុំជម្រះបានបដិសេធបណ្តឹងឧទ្ធរណ៍លើសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី ដោយផ្អែកទៅលើមូលដ្ឋានថា បណ្តឹងឧទ្ធរណ៍នេះបានលើកឡើងជាថ្មីម្តងទៀតអំពីសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការចូលរួមក្នុងកិច្ចស៊ើបសួរ ដែលបញ្ហានេះត្រូវបានអង្គបុរេជំនុំជម្រះបានពិចារណារួចហើយ ប៉ុន្តែ អង្គបុរេជំនុំជម្រះមិនអាចរកសម្លេងភាគច្រើនដែលត្រូវការដើម្បីចេញសេចក្តីសម្រេចបានទេនោះ[19]។

## II. ភាពអាចទទួលយកបាន

8. អង្គបុរេជំនុំជម្រះសូមរម្លឹកថា សញ្ញាណនៃការបដិសេធតាមការសន្មត ត្រូវបានអង្គជំនុំជម្រះបង្កើតឡើងសម្រាប់ស្ថានភាពទាំងឡាយ ដែលសហចៅក្រមស៊ើបអង្កេតខកខានមិនបានសម្រេចទៅលើសំណើសុំ ក្នុងរង្វង់ពេលវេលាដែលច្បាប់បានកំណត់ នៅពេលដែលអាចអនុវត្តបាន ឬនៅក្នុងករណីដែលការពន្យារពេលវេលារបស់សហចៅក្រមស៊ើបអង្កេតក្នុងការរៀបចំចេញសេចក្តីសម្រេច អាចដកហូតពីភាគីស្មើនូវប្រយោជន៍ផ្សេងៗដែលភាគីចង់បាន[20]។ ម្ចាស់បណ្តឹងឧទ្ធរណ៍ជំទាស់តវ៉ាថា ចំណុចទីពីរនេះអនុវត្តចំពោះស្ថានភាពបច្ចុប្បន្ននេះបាន។

---

[17] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២១, ២៦-២៧។

[18] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២១។

[19] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D185/1/1/2។

[20] *សូមមើល ក្នុងចំណោមនោះគឺ* ៖ សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០២") (អបជ ៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស ចំពោះសំណើសុំ D153, D172, D173, D174, D178 និង D284 (សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១២ របស់ នួន ជា) ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ D300/1/5

9. អង្គបុរេជំនុំជម្រះយល់ឃើញថា ករណីបច្ចុប្បន្ននេះមិនបង្ហាញឲ្យឃើញពីការពន្យារពេលវេលានៅក្នុងការពិចារណារបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើលើកទីបួននោះទេ។ ផ្ទុយទៅវិញ ស.ច.ស.អ បានសម្រេចមិនទទួលយកសំណើលើកទីបួននៅក្នុងដំណាក់កាលនេះទេ ដោយផ្អែកទៅលើការយល់ឃើញរបស់គាត់កាលពីមុនថា ម្ចាស់បណ្តឹងឧទ្ធរណ៍ពុំមានសិទ្ធិដាក់សំណើសុំបំពេញកិច្ចស៊ើបសួរទេ។ សេចក្តីសម្រេចនេះត្រូវបានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹង ដែលត្រូវអានជាមួយនឹងដីកាសម្រេចលើសំណើចំនួនបី។ ក្នុងកាលៈទេសៈទាំងនេះ ទ្រឹស្តីនៃការបដិសេធតាមការសន្មត មិនអាចយកមកអនុវត្តបានទេ ហើយការជំទាស់តវ៉ាទៅនឹងចំណាត់ការរបស់ ស.ច.ស.អ ត្រូវតែធ្វើចំពោះសេចក្តីជូនដំណឹង និង/ឬ ដីកាសម្រេចលើសំណើទាំងបី។ ត្រង់ចំណុចនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា តាមខ្លឹមសារ បណ្តឹងឧទ្ធរណ៍នេះជំទាស់តវ៉ាទៅនឹងសេចក្តីសម្រេចរបស់ ស.ច.ស.អ ក្នុងការមិនដាក់សំណើទីបួនទៅក្នុងសំណុំរឿង និងចំណុចទូទៅជាងនេះទៀតនោះ គឺ "គោលនយោបាយ" របស់គាត់ក្នុងការមិនយល់ព្រមតាមសំណើរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍សុំបំពេញកិច្ចស៊ើបសួរ ដូចដែលបានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹង និងដីកាសម្រេចលើសំណើទាំងបី។ អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះគឺជាការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីជូនដំណឹង ដូច្នេះ ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ នឹងត្រូវបានយកមកពិនិត្យនៅក្នុងបរិបទនេះ។

10. អនុលោមតាមវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង ការដាក់សារណាបណ្តឹងនៅចំពោះមុខអង្គបុរេជំនុំជម្រះ ត្រូវធ្វើនៅក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃគិតពីថ្ងៃបានទទួលសេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចដែលរងការជំទាស់។ សេចក្តីជូនដំណឹងនេះត្រូវបានបញ្ជូនទៅម្ចាស់បណ្តឹងឧទ្ធរណ៍កាលពីថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ហើយបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់កាលពីថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤។ ហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍នេះគឺហួសពេលទៅហើយ។ អនុលោមតាមវិធាន ៣៩(៤)(ខ) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះ "តាមរយៈពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬតាមការផ្តួចផ្តើមរបស់ខ្លួន អាចទទួលស្គាល់សុពលភាពនៃកិច្ចណាមួយដែលបានធ្វើក្រោយពេលកំណត់ ដែល

---

("សាលដីកាលើបណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១២") កថាខណ្ឌ ២០ *ដែលយោងទៅ* សំណុំរឿង ០០២ (អបជ ១០)។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញចិត្តសាស្ត្រ ឯកសារ A189/I/8 ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៨ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ស្តីពីការចាត់តាំងអ្នកជំនាញចិត្តសាស្ត្រ") កថាខណ្ឌ ២២-២៤។

មានចែងក្នុងវិធានផ្ទៃក្នុងនេះ ប្រសិនបើខ្លួនយល់ឃើញថា ត្រឹមត្រូវសមហេតុផល"[21]។ ក្នុងករណីមិនមានសំណើសុំពន្យារពេលវេលាពីម្ចាស់បណ្តឹងឧទ្ធរណ៍ទេ នោះអង្គបុរេជំនុំជម្រះត្រូវពិនិត្យ ថាតើកាលៈទេសៈទាំងនេះ តម្រូវឱ្យអង្គបុរេជំនុំជម្រះទទួលស្គាល់សុពលភាពនៃបណ្តឹងឧទ្ធរណ៍ ដែលត្រូវបានដាក់ហួសពេលកំណត់ដែរឬក៏អត់។

11. អង្គបុរេជំនុំជម្រះយល់ឃើញថា ទ្រឹស្តីនៃការបដិសេធតាមការសន្មត ដែលអង្គបុរេជំនុំជម្រះបានអនុវត្តសម្រាប់កាលៈទេសៈពិសេសទាំងឡាយ ដែលការិយាល័យសហចៅក្រមស៊ើបអង្កេតមិនមានសកម្មភាព ឬការពន្យារពេលវេលាក្នុងការបំពេញកិច្ច អាចបណ្តាលឱ្យមានព្យសនកម្ម មិនអាចត្រូវបានយកមកប្រើប្រាស់ ដើម្បីគេចពីពេលវេលាកំណត់សម្រាប់ការដាក់បណ្តឹងឧទ្ធរណ៍អនុលោមតាមវិធានផ្ទៃក្នុងបានទេ។ ហេតុដូច្នេះ ការកំណត់ចរិតលក្ខណៈនៃបណ្តឹងឧទ្ធរណ៍មិនត្រឹមត្រូវ មិនមែនជាមូលហេតុល្អមួយសម្រាប់ការទទួលយកការដាក់បណ្តឹងឧទ្ធរណ៍ដែលហួសពេលវេលាកំណត់ទៅហើយ ដោយមិនមានយុត្តិកម្មបន្ថែមណាមួយពីម្ចាស់បណ្តឹងឧទ្ធរណ៍នោះទេ។

## II. សេចក្តីសម្រេច

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទដូចខាងក្រោម÷**

**បដិសេធ** បណ្តឹងឧទ្ធរណ៍នេះដោយកំណត់ថា មិនអាចទទួលយកបាន។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះត្រូវបិទផ្លូវតវ៉ា។

ភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៤

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

ប្រាក់ គឹមសាន Rowan DOWNING **ន៉ី ធុល** Chang-ho CHUNG **ហួត វុទ្ធី**

[21] *សូមមើលផងដែរ* វិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះពន្យារពេលកំណត់ក្នុងការដាក់បណ្តឹងឧទ្ធរណ៍នៅក្រោម "កាលៈទេសៈពិសេស"។